អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃនេះ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចាប់ផ្តើមសវនាការដែលមានរយៈពេលបីថ្ងៃ នៅក្នុងសំណុំរឿង ០០៣ ប្រឆាំង មាស មុត។

ជាកិច្ចចាប់ផ្តើម ប្រធានអង្គជំនុំជម្រះប្រកាសបើកសវនាការជាសាធារណៈ បន្ទាប់មកមានការអានរបាយការណ៍នៃសំណុំរឿងនេះជាសាធារណៈ ដែលលើកឡើងនូវអង្គហេតុពាក់ព័ន្ធនានា និងប្រវត្តិនីតិវិធីនៃសំណុំរឿង ០០៣ ព្រមទាំងសេចក្តីលម្អិតនៃបណ្តឹងឧទ្ធរណ៍នានាដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ របាយការណ៍នេះត្រូវបានចេញក្នុងនាមអង្គបុរេជំនុំជម្រះទាំងមូល និងបានដាក់បញ្ចូលទៅក្នុងសំណុំរឿង។

សំណៅកោសលុបនៃរបាយការណ៍នេះអាចរកមើលបាននៅលើគេហទំព័រ៖
https://eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/D266_15_KH-Redacted.PDF

បន្ទាប់មក សវនាការបានដំណើរការជាអសាធារណៈ ដែលក្នុងអំឡុងពេលនោះ សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិបានបង្ហាញនូវអំណះអំណាងទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន។ សវនាការនឹងបន្តដំណើរការនៅថ្ងៃទី២៨ និងថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ តទៅទៀត អនុលោមទៅតាមដីកាកំណត់កាលវិភាគសម្រាប់សវនាការ ដែលបានចេញនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨។

***សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖***
លោក នេត្រ ភក្ត្រា
ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ
ទូរស័ព្ទចល័ត+៨៥៥(0)១២៤៨៨១៥៦
ទូរស័ព្ទលើតុ: +៨៥៥(0)២៣៨៦១៥៦៤
អ៊ីមែល: neth.pheaktra@eccc.gov.kh